# លទ្ធផលការងារសំខាន់ៗ ឆ្នាំ២០២៥

# និងទិសដៅការងារសំខាន់ៗ ឆ្នាំ២០២៦

# របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦

# ១. ការអភិវឌ្ឍមុខរបរ និងការងារក្នុងស្រុក

# ការអនុវត្តអនុសាសន៍ទាំង ១០ ចំណុចរបស់ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

**ប្រាក់ឈ្នួលអប្បបរមា**
២១០ ដុល្លារអាមេរិក/ខែ

**របបភាគទានដោយស្ម័គ្រចិត្ត**
ចុះបញ្ជិកាសមាជិក ៣២,៦ ម៉ឺននាក់

**កម្មវិធីធីវេត ១,៥លាននាក់**
សិស្សទទួលបានការបណ្តុះបណ្តាល ១២,៥ ម៉ឺននាក់

**ភាតព្វកិច្ចហ្វឹកហ្វឺនកូនជាង**
ចំនួនកូនជាង ៤,៤ ម៉ឺននាក់

**ឧបត្ថម្ភស្ត្រីមានផ្ទៃពោះ កុមារអាយុក្រោម ២ឆ្នាំ**
ស្ត្រីមានផ្ទៃពោះ ចំនួន ១២,៣ម៉ឺននាក់ និង
កុមារអាយុក្រោម ២ឆ្នាំ ចំនួន ១៧ម៉ឺននាក់

**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**
ប្រគល់ពានរង្វាន់ជាលើកដំបូងចំនួន ៣៦ សហគ្រាស

**ការកែលម្អកន្លែងហូបបាយ ឬអាហារដ្ឋាន**
សហគ្រាស ១ ៤៧៩ ជំរុញការកែលម្អ និង
២២ សហគ្រាសបង្កើតថ្មី

**ការកែលម្អមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត**
រថយន្តដឹកអ្នកដំណើរចំនួន ១ ៤២៤គ្រឿង លើ ៣ ២៤៨គ្រឿង
បានត្រួតពិនិត្យបច្ចេកទេស និងបានធ្វើយុទ្ធនាការ ១លើក

**ការអនុវត្តភាតព្វកិច្ចសេវាទារកដ្ឋាន**
បានដាក់ដំណើរការទារកដ្ឋានចំនួន ១ និងផ្តល់ជម្រើសផ្តល់
ជាប្រាក់ឧបត្ថម្ភដល់ស្ត្រី ដែលមានទារករហូតអាយុ២ឆ្នាំ

**ការធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព**
**ទទួលស្គាល់ជំនាញពីមុន** (RPL)
បានធ្វើតេស្តកម្មករនិយោជិតជាង ៤ពាន់នាក់
បានចុះបញ្ជីទទួលស្គាល់មជ្ឈមណ្ឌលធ្វើតេស្ត ១៥
បណ្តុះបណ្តាលអ្នកវាយតម្លៃ ចំនួន ៥៦៤នាក់

# សហគ្រាស ក្រុមហ៊ុន ពេខចក្រភ្លួខប្រព័ន្ធ

បម្រែបម្រួល (គិតជាសហគ្រាស)

**កើនឡើង** ▲ **1,851** សហគ្រាស



# សហគ្រាសវិស័យកាត់ដេរ និងក្រៅពីវិស័យកាត់ដេរ

**វិស័យកាត់ដេរ** | បម្រែបម្រួល (គិតជាសហគ្រាស) | **ក្រៅពីវិស័យកាត់ដេរ**

កើនឡើង ▲ **301** សហគ្រាស | ▲ **1,550** សហគ្រាស



# កម្មករនិយោជិតក្នុងប្រព័ន្ធ

បម្រែបម្រួល (គិតជានាក់)

កើនឡើង ▲ **401,479** នាក់



# កម្មករនិយោជិតវិស័យកាត់ដេរ និងក្រៅពីវិស័យកាត់ដេរ

| វិស័យកាត់ដេរ | បម្រែបម្រួល (គិតជានាក់) | ក្រៅពីវិស័យកាត់ដេរ |
|---|---|---|
| ▲ 210,046 នាក់ | កើនឡើង | ▲ 191,433 នាក់ |
| 1,134,091 | 2025 | 1,083,434 |
| 924,045 | 2024 | 892,001 |

# រៀបចំវេទិកាការងារ និងផ្តល់ឱកាសការងារ

- បានរៀបចំវេទិកា និងពិព័រណ៍ការងារ **១ ៣៣៩លើក** (អ្នកចូលរួមប្រមាណ **៣៤,១ម៉ឺននាក់**)

- បានផ្តល់ការប្រឹក្សាមគ្គុទេសក៍អាជីពដល់យុវជន និងអ្នកស្វែងរកការងារសរុបចំនួន **៧,២ម៉ឺននាក់** (ស្រីប្រមាណ ៣,៨ម៉ឺននាក់)





## សន្និសីទថ្នាក់ជាតិ ស្តីពី សេដ្ឋកិច្ចការងារ ឆ្នាំ២០២៥ ក្រោមប្រធានបទ «ការរៀបចំអនាគតការងារ នៅកម្ពុជា៖ ជំនាញ មុខរបរនិងការងារ និងការគាំពារសង្គម សំដៅបង្កើតទីផ្សារការងារ ដែលមានភាពធន់»






គោលបំណងជំរុញកិច្ចសហការ ការផ្លាស់ប្តូរចំណេះដឹងនិងនវានុវត្តន៍ ការស្វែងយល់ពីបញ្ហាប្រឈម និងឱកាសក្នុងការធ្វើឱ្យប្រសើរឡើង នូវទីផ្សារការងារ តាមរយៈកិច្ចពិភាក្សា និងការចែករំលែកចំណេះដឹង

# ដើម្បីគាំទ្រដល់ការស្រាវជ្រាវ និងស្វែងយល់ពីនិន្នាការទីផ្សារការងារ ក្រសួងបានធ្វើការសិក្សា និងបោះពុម្ពផ្សាយទស្សនវិស័យមុខរបរនិងការងារ និងរបាយការណ៍អង្កេតជាច្រើន











- របាយការណ៍អង្កេត «**ទស្សនវិស័យការងារកម្ពុជា**» ចំនួន ២
- ឯកសារ «**ទស្សនវិស័យមុខរបរ និងការងារ**» ចំនួន ២លេខ នៅឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២៥ ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយ និងបានផលិត ឯកសារ «**ទស្សនវិស័យមុខរបរ និងការងារ**» លេខ ៥ ឆមាសទី១ ឆ្នាំ២០២៦
- សិក្ខាសាលាផ្សព្វផ្សាយឯកសារ «**ទស្សនវិស័យមុខរបរ និងការងារ៖ តម្រូវការជំនាញ និងការងារសម្រាប់យុវជន**» ត្រូវបានរៀបចំចំនួន ២លើក។




# ២. ការអន្តរាគមន៍ដោះស្រាយការទារ ជូនបងប្អូនពលករត្រឡប់មកពីប្រទេសថៃ

# ក្រសួង បានចូលរួមអន្តរាគមន៍តាមច្រកព្រំដែនទាំង ៦ ដល់ពលករខ្មែរដែលវិលត្រឡប់ ពីប្រទេសថៃ សរុបប្រមាណជាង ៩៥ម៉ឺននាក់











# ការអន្តរាគមន៍ផ្តល់ព័ត៌មានទីផ្សារការងារ និងឱកាសបណ្តុះបណ្តាលនៅតាមច្រកព្រំដែន










# យុទ្ធនាការទាក់ទងទៅគ្រប់ពលករ ដែលបានចុះឈ្មោះស្វែងរកការងារធ្វើ និងបំពេញព័ត៌មានតាមរយៈប្រព័ន្ធឆ្លើយតបរហ័ស ១២៩៧ ឬតាម តេឡេក្រាមរបស់ក្រសួង





# សហការជាមួយភាគីពាក់ព័ន្ធក្នុងយុទ្ធនាការ ខ្មែរជួយរកការងារឱ្យខ្មែរ
# និងដាក់ចេញវិធានការបន្ទាន់ផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការវិលត្រឡប់របស់ពលករខ្មែរ






















# ២០២៥

ផ្សព្វផ្សាយតាម Billboard **សរុប ៤៦ទីតាំង** ៖ Billboard LED ចំនួន ២៩ទីតាំង និង Billboard PVC ចំនួន ១៧ទីតាំង

# ២០២៦

គ្រោងផ្សព្វផ្សាយ Billboard **សរុប ១៦៥ ទីតាំងបន្ថែម** ទៀតនៅ ១៦ ខេត្ត

# រៀបចំវេទិកាការងារ និងរៀបចំពិព័រណ៍ការងារតាមបណ្តាខេត្តសរុបបាន ចំនួន ៥៧៩លើក និងបន្តរៀបចំពិព័រណ៍នេះបន្ថែមនៅតាមបណ្តាខេត្ត




**ចាប់ពីខែមិថុនា ដល់ ខែធ្នូឆ្នាំ២០២៥**

- បានរៀបចំវេទិកាការងារ និងពិព័រណ៍ការងារ **៥៧៩ លើក**
- នៅ៖

**១៧ ខេត្ត**

**១៤២ ស្រុក**

**៤៣៧ ឃុំ**

អ្នកចូលរួម

**១៥ ម៉ឺននាក់**

# ថ្នាក់ដឹកនាំក្រសួង បានចុះតាមរោងចក្រចំនួន ១ ៦០៤រោងចក្រ ដើម្បីផ្សព្វផ្សាយ ជួយពន្យល់ដោយផ្ទាល់ដល់អ្នកគ្រប់គ្រងរោងចក្រឱ្យមានការយោគយល់ចំពោះបងប្អូនពលករ និងឱ្យជួយបង្ហាត់បង្រៀនបងប្អូនពលករដែលទើបចូលធ្វើការថ្មី









# ជាលទ្ធផលនៃអន្តរាគមន៍ឥតឈប់ឈររបស់ក្រសួង ពលករខ្មែរប្រមាណ ៦២ម៉ឺននាក់បានទទួលការងារ ក្នុងនោះប្រមាណ ៣១ម៉ឺននាក់ បានចូលធ្វើការងារក្នុងប្រព័ន្ធ

ពលករខ្មែរបានវិលត្រឡប់ពីថៃ ទទួលបានការងារ **៦២ម៉ឺននាក់**

«ក្នុងនោះ **៣១ម៉ឺននាក់** បានចូលធ្វើការងារ ក្នុងប្រព័ន្ធ ខណៈ **៣១ម៉ឺននាក់** ផ្សេងទៀត បានធ្វើការ និងប្រកបរបរផ្សេងទៀត ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ»










# ៣. ការពង្រឹងលក្ខខណ្ឌការងារ និងសុវត្ថិភាព និងសុខភាពការងារនៅទីកន្លែងការងារ

# ក្រសួងបានជំរុញការអនុវត្តប្រព័ន្ធស្វ័យប្រកាសអធិការកិច្ចការងារ ដោយធ្វើអធិការកិច្ចការងារ សរុប ១,៣ម៉ឺន លើក និងបានផាកពិន័យ ១០១ សហគ្រាស

## ការធ្វើអធិការកិច្ចការងារ




## ការផាកពិន័យ



# ការធ្វើអធិការកិច្ចការងារលើការប្រើប្រាស់កម្មករនិយោជិតវ័យក្មេង និងពលកម្មកុមារ ត្រូវបានបង្កើន ព្រមទាំងបង្កើនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ

## ការធ្វើអធិការកិច្ចការងារកុមារ

កើនសរុប ១៥៥ លើក




## ការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ

កើនសរុប ១៣៥ លើក




## ការបណ្តុះបណ្តាលស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ




ប្រភព៖ នាយកដ្ឋានការងារកុមារ

# សមាសភាពក្រុមអធិការកិច្ចការងារ ជាមួយកាបូបដាក់ឯកសារច្បាប់ និងសម្ភារៈបច្ចេកទេសសម្រាប់ចុះអធិការកិច្ចការងារ





សមាសភាព ៥រូប រួមមាន៖ អធិការការងារក្រសួង, មន្ទីរ, ការងារកុមារ, ពេទ្យការងារ, ប.ស.ស.



បានពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងបំពាក់សម្ភារៈ បរិក្ខារ សម្រាប់ចុះអធិការកិច្ចការងារ

# បានពង្រឹងសមត្ថភាពអធិការពេទ្យការងារ និងបំពាក់ឧបករណ៍ សម្ភារៈ សម្រាប់ចុះអធិការកិច្ចការងារ ផ្នែកសុវត្ថិភាពនិងសុខភាពការងារ (OSH)





# ឧបករណ៍ សម្ភារៈ សម្រាប់ អធិការកិច្ចការងារ ផ្នែកសុវត្ថិភាពនិង សុខភាពការងារ (OSH)



# ឧបករណ៍ សម្ភារៈ សម្រាប់ចុះអង្កេតគ្រោះថ្នាក់ការងារនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ



ឧបករណ៍វាស់ និងកំណត់ឧស្ម័នគ្រោះថ្នាក់ដែលសាយភាយចេញពីដំណើរការផលិតកម្មរោងចក្រ




ឧបករណ៍វាស់កម្រិតឧស្ម័នក្នុងខ្យល់



ឧបករណ៍ T363S Digital Anemometer វាស់ល្បឿនខ្យល់ និងសីតុណ្ហភាព



ឧបករណ៍ Multi-Function Environment 4-in-1 វាស់ល្បឿនខ្យល់ និងសីតុណ្ហភាព



ឧបករណ៍វាស់កម្រិតសំឡេងរំខាន



ឧបករណ៍ Air-Quality Meter ត្រួតពិនិត្យលើកម្រិតគុណភាពខ្យល់ សីតុណ្ហភាព និងឧស្ម័នដែលមានគ្រោះថ្នាក់



ឧបករណ៍វាស់កម្រិតពន្លឺ



ឧបករណ៍វាស់កម្រិតទទួលរងនូវសំឡេងបំពាក់លើបុគ្គល

ប្រភព៖ នាយកដ្ឋានពេទ្យការងារ

# ការផ្តល់សេវាសាធារណៈក្នុងការពិនិត្យកាយសម្បទា

កើនឡើង ▲ **134 820** នាក់



# ៤. ការពង្រឹងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

# ទន្ទឹមនេះ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈត្រូវបានលើកកម្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈ កំណើនជាបន្តបន្ទាប់ នៃការចុះបញ្ជីរបស់អង្គការវិជ្ជាជីវៈ បន្ទាប់ពីប្រកាសឱ្យអនុវត្តច្បាប់ស្តីពីសហជីព

## អង្គការវិជ្ជាជីវៈសរុបដែលបានចុះបញ្ជី

កើនសរុប ៣៣៧




## សហភាពសហជីព

កើនសរុប ០




## សហព័ន្ធសហជីព

កើនសរុប ៤




## សហជីពមូលដ្ឋាន

កើនសរុប ៣៣២




## សមាគមនិយោជក

កើនសរុប ១



# ការដោះស្រាយវិវាទការងារ

## អត្រាសះជានៃការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ







ប្រភព៖ នាយកដ្ឋានវិវាទការងារ

# ការដោះស្រាយកូដកម្ម និងបាតុកម្ម

## ចំនួនករណីកូដកម្ម និងអត្រាដោះស្រាយសះជា




## ចំនួនករណីបាតុកម្ម និងអត្រាដោះស្រាយសះជា



# សមាសភាពមន្ត្រីចុះដោះស្រាយវិវាទការងារ

មន្ត្រីនៃនាយកដ្ឋានវិវាទការងារ, អធិការការងារ, មន្ត្រីនៃមន្ទីរ ក.ប. និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានគណៈកម្មការ
សម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា








## សមាសភាពមន្ត្រីចុះដោះស្រាយវិវាទការងារ ជាមួយកាបូបដាក់ឯកសារ និងឯកសារពាក់ព័ន្ធ

( ច្បាប់ស្ដីពីការងារ, ច្បាប់ស្ដីពីសហជីព, ក្រមសីលធម៌, កម្រងបទដ្ឋានគតិយុត្ត, ប្រវត្តិក្រុមហ៊ុន )


L.SOPHEAK
L.INSPECTOR




Mini AI
Title/Department


Mini AI
Title/Department

# ៥. ការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ

# ការកំណត់ប្រាក់ឈ្នួលអប្បបរមា

## ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០២៦

**២១០ ដុល្លារអាមេរិក/ខែ**
កម្មករនិយោជិតពេញសិទ្ធិ

**២០៨ ដុល្លារអាមេរិក/ខែ**
កម្មករនិយោជិតសាកល្បង

**២២៧ ដល់ ២៣៨ ដុល្លារអាមេរិក/ខែ**
ប្រាក់ឈ្នួលទាបបំផុត
(បូកទាំងអត្ថប្រយោជន៍ផ្សេងៗ)

## លក្ខណវិនិច្ឆ័យក្នុងការកំណត់

### លក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច

- ផលិតភាព
- ភាពប្រកួតប្រជែងរបស់ប្រទេស
- ស្ថានភាពទីផ្សារការងារ
- កម្រិតចំណេញរបស់វិស័យ

### លក្ខណវិនិច្ឆ័យបែបសង្គម

- ស្ថានភាពគ្រួសារ
- អត្រាអតិផរណា
- ការចំណាយក្នុងការរស់នៅ

## សមាសភាពចូលរួមកំណត់ប្រាក់ឈ្នួលអប្បបរមា

- តំណាងភាគីកម្មករនិយោជិត
- តំណាងភាគីនិយោជក
- តំណាងភាគីរាជរដ្ឋាភិបាល

# ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមារបស់កម្ពុជាពីឆ្នាំ ១៩៩៧ ដល់ ២០២៦



# ប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជា ធៀបនឹងបណ្ដាប្រទេសមួយចំនួន ក្នុងឆ្នាំ២០២៥




**សម្គាល់៖** ប្រាក់ឈ្នួលអប្បបរមានៃប្រទេសមួយចំនួនត្រូវបានគិតជារូបិយវត្ថុក្នុងស្រុក នៃប្រទេសរៀងៗខ្លួន។ ដូច្នេះ អត្រាប្រាក់ឈ្នួលអប្បបរមាគិតជាដុល្លារអាមេរិក អាចប្រែប្រួលពីមួយខែទៅមួយខែ អាស្រ័យលើគោលនយោបាយរូបិយវត្ថុនៃប្រទេសទាំងនោះ។
**ប្រភព៖** ការចងក្រងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយផ្អែកលើស្ថិតិជាតិ, អត្រាប្ដូរប្រាក់គឺជាអត្រាប្ដូរប្រាក់មធ្យមប្រចាំថ្ងៃនៃឆ្នាំ២០២៥ ទាញចេញពីធនាគារកណ្ដាលនៃប្រទេសនីមួយៗ។

# ដាក់ឱ្យអនុវត្តការប្រកួត និងជ្រើសរើសសហគ្រាសដើម្បីទទួលពានរង្វាន់
# «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ ប្រចាំឆ្នាំ២០២៥»

ក្រសួងបានជ្រើសរើស និងប្រគល់ពានរង្វាន់ជាលើកដំបូងដល់សហគ្រាស **ចំនួន ៣៦** ក្នុងនោះ

ពានមាសចំនួន **២២ សហគ្រាស**, ពានប្រាក់ចំនួន **៥ សហគ្រាស**, ពានសំរឹទ្ធចំនួន **៩ សហគ្រាស**







# ការរៀបចំឱ្យមានទារកដ្ឋាន ឬផ្តល់ជាប្រាក់ឧបត្ថម្ភ

| ការរៀបចំឱ្យមានទារកដ្ឋាន | ឧបត្ថម្ភដល់កម្មការិនី ដែលមានកូនរហូតដល់កូនមានអាយុ ២ឆ្នាំ |
|---|---|






# ជំរុញការកែលម្អកន្លែងហូបបាយ ឬអាហារដ្ឋាននៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលកំពុងដំណើរការឱ្យបានសមរម្យសម្រាប់កម្មករនិយោជិត





## កន្លែងហូបបាយ ឬអាហារដ្ឋាននៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ

**១ ៤៧៩ សហគ្រាស**

ជំរុញការកែលម្អ

**២២ សហគ្រាស**

បង្កើតថ្មី

# កំពុងសិក្សារៀបចំផ្លាស់ប្តូររថយន្តដឹកជញ្ជូនកម្មករនិយោជិត



## រថយន្តដឹកជញ្ជូនកម្មករនិយោជិតក្នុងឆ្នាំ២០២៥ មានចំនួន ៣ ២៤៨គ្រឿង





# រថយន្តគំរូដែលត្រូវបានកែលម្អឱ្យមានកៅអីអង្គុយ និងដំបូលសមរម្យ





ប្រភេទរថយន្តដឹកជញ្ជូនកម្មករនិយោជិត




ពិធី "ប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត" នាព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ នៅតំបន់សេដ្ឋកិច្ចពិសេស មេនហាតធេន ក្រុងបាវិត ខេត្តស្វាយរៀង។

# ជំរុញការកែលម្អមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតឱ្យមានកៅអីអង្គុយ និងដំបូលសមរម្យ

## ២០២៥





## ២០២៦







# ៦. ការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព

# ការផ្តល់ឱកាសការងារក្រៅប្រទេសជូនពលរដ្ឋខ្មែរក្នុងឆ្នាំ២០២៥

**សរុប 23,435**




កើនឡើង 32% បើធៀបឆ្នាំ២០២៤ ( 5,093)

មុនមានការប៉ះទង្គិចតាមព្រំដែន

# ក្នុងឆ្នាំ២០២៥ ជនទេសន្តរប្រវេសន៍ការងារខ្មែរ កំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសមាន ប្រមាណ ៤៣,៣៦ម៉ឺននាក់ និងបានបញ្ជូនប្រាក់បញ្ញើមកប្រទេសវិញប្រមាណ ១,៨៦ ប៊ីលានដុល្លារអាមេរិក

## ជនទេសន្តរប្រវេសន៍ការងារខ្មែរតាមប្រទេសក្នុងឆ្នាំ២០២៥

**៤៣,៣៦ ម៉ឺននាក់**

**១,៨៦ ប៊ីលានដុល្លារអាមេរិក**

ប្រាក់បញ្ញើបញ្ជូន
មកប្រទេសវិញ

ព្រះរាជាណាចក្រថៃ
៣៤៥ ២១២នាក់

សាធារណរដ្ឋកូរ៉េ
៤៤ ៥៩១នាក់

ម៉ាឡេស៊ី
២១ ៩៤៨នាក់

ជប៉ុន
២១ ៥៩៥នាក់

សិង្ហបុរី
២០៣នាក់

ហុងកុង
៣៦នាក់

អារ៉ាប់ប៊ីសាអូឌីត
៩នាក់

អ៊ីស្រាអែល
៣៧នាក់

# ៧. ការពង្រីកវិសាលភាពគ្រប់ដណ្ដប់របបសន្តិសុខសង្គម

# សមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពតាមរបបភាគទាន ដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុក

សមាជិក តាមរបបភាគទានដោយស្ម័គ្រចិត្ត សរុប ចំនួន **៨៥៩ ៧២៦ នាក់** (ស្រី ៥១៥ ៥១៣ នាក់)

សមាជិកចុះបញ្ជិកាថ្មី ក្នុងឆ្នាំ២០២៥ ចំនួន **៣២៥ ៦៩០ នាក់** (ស្រី ១៩៣ ៧៧៤នាក់)



# សមាជិក ប.ស.ស. បានបន្តកើនឡើងជាលំដាប់ដល់ចំនួនជាង ៣,៥លាននាក់









# របបភាគទានដោយស្ម័គ្រចិត្ត បានកើនសមាជិកសរុបជាង ២២ម៉ឺននាក់ ក្នុងនោះសមាជិក ប.ស.ស. ដែលជាបុគ្គលស្វ័យនិយោជន៍ កើនជាង ១១ម៉ឺននាក់ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. កើនជាង ១១ម៉ឺននាក់



# សមាជិក ប.ស.ស. ចូលប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាលដៃគូ

**កើនឡើង ▲ 329,786 ដង**



# កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ (ពីរ) ឆ្នាំ

**ម្តាយ (នាក់)**

**696,751**

**កូន (នាក់)**

**732,123**

**ប្រាក់ឧបត្ថម្ភ (លានរៀល)**

**409,964.16**



# មុខងារបញ្ជរស្វ័យសេវារបស់ ប.ស.ស.

កំណត់អត្តសញ្ញាណសមាជិក ប.ស.ស. និងបោះពុម្ពលិខិតបញ្ជាក់
សុពលភាពបណ្ណសមាជិក ប.ស.ស. (Patient Form) មុនចូលប្រើប្រាស់
សេវាសុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលដៃគូ

បន្ថយបន្ទុករដ្ឋបាលលើការបញ្ចូលទិន្នន័យច្រើនដង ដោយការថ្លក់
ទិន្នន័យជាមួយមូលដ្ឋានសុខាភិបាលដៃគូ

ផ្តល់សិទ្ធិពេញលេញក្នុងការប្រើប្រាស់សេវាសុខាភិបាល
ទៅក្នុងដៃសមាជិក ប.ស.ស.




**គម្រោងនាពេលអនាគត៖** ថ្លក់ទិន្នន័យពេញលេញជាមួយមូលដ្ឋានសុខាភិបាលដៃគូ ដើម្បីឈានដល់ការស្នើសុំទូទាត់តាមអនឡាញពេញលេញ
ដោយស្វ័យប្រវត្តិ (មិនបាច់បញ្ចូលទិន្នន័យសារឡើងវិញដូចសព្វថ្ងៃ) និងតាមពេលវេលាជាក់ស្តែង (Real Time) ដោយមិនប្រើប្រាស់ក្រដាស

# អត្ថប្រយោជន៍បញ្ជរស្វ័យសេវារបស់ ប.ស.ស.







កាត់បន្ថយបន្ទុករដ្ឋបាលនិងបុគ្គលិកនៅមូលដ្ឋានសុខាភិបាល

ចំណេញពេលវេលា

សិទ្ធិប្រើប្រាស់សេវាសុខាភិបាលពេញលេញទៅក្នុងដៃសមាជិក ប.ស.ស.




# ទីតាំងដាក់ឱ្យប្រើប្រាស់បញ្ជរស្វ័យសេវារបស់ ប.ស.ស. នៅតាមមន្ទីរពេទ្យជាតិ ចំនួន១០ ស្មើនឹង២០គ្រឿង

- ❑ មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ ចំនួន៤គ្រឿង
- ❑ មជ្ឈមណ្ឌលជាតិគាំពារកំចាត់រោគរបេង និងហង់សិន ចំនួន១គ្រឿង
- ❑ មន្ទីរពេទ្យជាតិ តេជោសន្តិភាព ចំនួន៤គ្រឿង
- ❑ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ចំនួន១គ្រឿង
- ❑ មន្ទីរពេទ្យព្រះកេតុមាលា ចំនួន១គ្រឿង
- ❑ វិទ្យាស្ថានជាតិសុខភាពសាធារណៈ ចំនួន១គ្រឿង
- ❑ មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ចំនួន២គ្រឿង
- ❑ មន្ទីរពេទ្យហ្លួងម៉ែ ចំនួន២គ្រឿង
- ❑ មន្ទីរពេទ្យកុមារជាតិ ចំនួន២គ្រឿង
- ❑ មន្ទីរពេទ្យព្រះអង្គឌួង ចំនួន២គ្រឿង។

# ៨. ការធ្វើបរិវត្តកម្មការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ

# គ្រឹះស្ថានធីវេត ដែលត្រូវបានបញ្ចប់ និងកំពុងសាងសង់ក្នុងឆ្នាំ២០២៥



វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
ចំនួន ១ អគារ (៥ជាន់)



វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ
ចំនួន ១ អគារ (៦ជាន់) និង ១ អន្តេវាសិកដ្ឋាន (៥ជាន់)

## គ្រឹះស្ថានធីវេត ដែលត្រូវបានបញ្ចប់ និងកំពុងសាងសង់ក្នុងឆ្នាំ២០២៥



វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់
ចំនួន ១ អគារ (៥ជាន់)



វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង
ចំនួន ១ អគារ (៥ជាន់)



វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ
ចំនួន ១ អគារ (៤ជាន់)

# ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងការហ្វឹកហ្វឺនកូនជាង



## ២០,៧ម៉ឺននាក់

សិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិតដែលទទួលបានការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងការហ្វឹកហ្វឺនកូនជាង



## ១៤,៧ម៉ឺននាក់

បណ្តុះបណ្តាលនៅគ្រឹះស្ថានក្រោមឱវាទក្រសួង

## ១,៦ម៉ឺននាក់

បណ្តុះបណ្តាលតាមយន្តការ SDF

## ៤,៤ ម៉ឺននាក់

ការហ្វឹកហ្វឺនកូនជាង

# ការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (១,៥លាននាក់)

សិស្សដែលទទួលបានការបណ្តុះបណ្តាលក្នុងកម្មវិធី ១,៥លាននាក់

**១២,៥ ម៉ឺននាក់**

សិស្សដែលទទួលបានការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានក្រោមឱវាទក្រសួង

**១០,៩ ម៉ឺននាក់**

សិស្សដែលទទួលបានការបណ្តុះបណ្តាលតាមយន្តការមូលនិធិអភិវឌ្ឍន៍ជំនាញ

**១,៦ ម៉ឺននាក់**

# ការធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ជំនាញពីមុន (RPL)



ធ្វើតេស្តវាយតម្លៃជូនបង
ប្អូនកម្មករនិយោជិតទាំងក្នុង
និងក្រៅប្រព័ន្ធ
ចំនួន ៤ ០៧៥ នាក់



ទទួលស្គាល់មជ្ឈមណ្ឌល
វាយតម្លៃសមត្ថភាព
ចំនួន ១៥
(គ្រឹះស្ថានឯកជនចំនួន ៣)



បណ្តុះបណ្តាលគ្រូ និង
អ្នកបច្ចេកទេសឱ្យក្លាយជា
អ្នកវាយតម្លៃសមត្ថភាព
ចំនួន ៥៦៤ នាក់

# ការរៀបចំគុណវុឌ្ឍិ និងម៉ូឌុលសិក្សាក្នុងវិស័យអាទិភាពទាំង ១០



**កញ្ចប់ស្តង់ដាបណ្តុះបណ្តាល**
**ចំនួន ២៥៦ គុណវុឌ្ឍិ**
**(គ្រប់ដណ្តប់លើ ១១៦មុខជំនាញ)**



**កញ្ចប់សិក្សាផ្អែកលើសមត្ថភាព**
**ចំនួន ៣៩៩ ម៉ូឌុល**
**(ស្មើនឹង ២ ៦២០មេរៀន)**

# ទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៨ ឆ្នាំ២០២៥





ក្រោមប្រធានបទ «TVET បង្កើតឱកាសការងារ សាងក្ដីសង្ឃឹមដល់យុវជន»

**អ្នកចូលរួមចំនួន ៦,៦ម៉ឺននាក់**

# កិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានពង្រឹង និងមានកំណើនជាបន្តបន្ទាប់ ដោយក្នុងឆ្នាំ២០២៥ បានចុះ MOU សរុប ៥០៧ (កើនចំនួន ១០៩) និងដៃគូធំនាក់ធំនង សហការ សរុប ២ ៧០១ (កើនចំនួន ៣១៦)

**MOU និង ដៃគូសហការ**

- ២០ — MOU ជាមួយគ្រឹះស្ថានជាតិ
- ៥០ — MOU ជាមួយគ្រឹះស្ថានអន្តរជាតិ
- ៤៣៧ — MOU ជាមួយវិស័យឯកជន
- ២ ៦៣៤ — ដៃគូក្នុងប្រទេស
- ៦៧ — ដៃគូក្រៅប្រទេស

# នាំយកចំណេះដឹងនិងជំនាញវិជ្ជាជីវៈ ទៅដល់មូលដ្ឋានតាមរយៈ «កម្មវិធីបណ្តុះបណ្តាលជំនាញចល័ត»



# ការបណ្តុះបណ្តាលដើរទៅរកសិស្ស៖ ពីតុតូចលើរ៉ឺម៉ក ទៅជាថ្នាក់រៀនធំនើបតាមរថយន្ត

| ថ្នាក់បណ្តុះបណ្តាលចល័ត ឆ្នាំ២០២៥ | | ថ្នាក់បណ្តុះបណ្តាលចល័ត ឆ្នាំ២០២៦ |
|---|---|---|
|  | → |  |





**ផ្លាស់ប្តូរពីការរៀនក្នុងថ្នាក់ ទៅជាការរៀនពីចម្ងាយ( កន្លែងធ្វើការ ឬគេហដ្ឋាន )**

# ការពិនិត្យលទ្ធភាពបំពាក់ឧបករណ៍សម្ភារៈតាមប្រភេទត្រីចក្រយានយន្ត












ទទួលការបណ្តុះបណ្តាល

បណ្តើរ ធ្វើការបណ្តើរ៖

ជំនាញក៏កើន

ប្រាក់ចំណូលក៏កើន





# ៩.ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ

# បន្ត និងពង្រឹងការអនុវត្តច្បាប់តាមរយៈការបណ្តុះបណ្តាលថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទក្រសួង រដ្ឋបាលរោងចក្រ សហជីព និងប្រតិភូបុគ្គលិក ដើម្បីធានាគុណភាពដឹកនាំ និងការអនុវត្តការងារឱ្យកាន់តែប្រសើរ

## ការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព



# ដើម្បីផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរ និងបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព មន្ត្រីរាជការ ត្រូវបានបញ្ជូនចូលរួមវគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស

## ស្ថិតិការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ



# បណ្ដុះបណ្ដាលមន្ត្រីឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល ( DMS ) ឱ្យកាន់តែស្ទាត់ជំនាញ

**គិតត្រឹមថ្ងៃទី** 25-02-2026 **ម៉ោង** 21:31:04 **នាទី**

**ទិន្នន័យឯកសារចូលសរុប ៖**

| | |
|---|---|
| ឯកសារទូទៅ | 199 |
| ឯកសារចំឈ្មោះ | 36 |
| ឯកសារសម្ងាត់ | 0 |
| ឯកសារបញ្ជូនបន្ត | 34 |

**ទិន្នន័យឯកសារឆ្លងថ្នាក់ដឹកនាំសរុប ៖**

| | |
|---|---|
| ឯកសារទូទៅ | 2 |
| ឯកសារប្រញាប់ | 0 |

# ធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈនិងសេវាគាំទ្រទូទៅតាមបច្ចេកវិទ្យាឌីជីថល

សហការជាមួយ **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
ក្នុងការរៀបចំសារខ្លី បញ្ជូនទៅគ្រប់ទូរសព្ទ




សហការជាមួយ **ក្រសួងព័ត៌មាន**

ផ្សព្វផ្សាយជាអក្សររត់នៅតាមកម្មវិធីផ្សាយនានា
របស់ទូរទស្សន៍ជាតិកម្ពុជា

អនុវត្ត **យន្តការលើកទឹកចិត្ត**
**និងទណ្ឌកម្មខាងវិន័យ**

ចំពោះមន្ត្រីរាជការ ដើម្បីបង្កើន
ប្រសិទ្ធភាពការងារ

បានចុះ **អនុស្សរណៈនៃការយោគយល់គ្នា**
ក្នុងការផ្សព្វផ្សាយកម្មវិធីអប់រំបណ្តុះបណ្តាល
ជំនាញវិជ្ជាជីវៈ និងបច្ចេកទេស

ជាមួយសមាគមសិល្បៈ
និងស្ថាប័នឯកជនផ្សេងទៀត

**ប្រព័ន្ធ** Hotline
លេខ **១២៨៦** និង **១២៩៧**

# បង្ខិតការផ្តល់សេវាសាធារណៈ ឱ្យកាន់តែជិតក្រុមគោលដៅ
# ដើម្បីប្រយោជន៍កម្មករនិយោជិត អ្នកស្វែងរកការងារធ្វើ និងនិយោជក









ក្រសួងបានដាក់ឱ្យប្រើប្រាស់បញ្ជរសេវាសាធារណៈចល័តចំនួន ១០០គ្រឿង
និងគ្រោងផលិតនិងដាក់ឱ្យប្រើប្រាស់ចំនួន ៩០០គ្រឿងបន្ថែមទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ
ពង្រីកសាខា ប.ស.ស. និងមជ្ឈមណ្ឌលការងារនៅផ្សារទំនើបអ៊ីអន និងទីតាំងផ្សេងទៀត

# បន្តធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅតាមបច្ចេកវិទ្យាឌីជីថល ដើម្បីឱ្យកាន់តែមានភាពងាយស្រួល និងងាយយល់ក្នុងការប្រើប្រាស់

## ប្រព័ន្ធទទួលបណ្តឹងអនាមិក

**(feedback.mlvt.gov.kh)**




## ប្រព័ន្ធតាមដានវឌ្ឍនភាពសេវាសាធារណៈក្រសួង

**(tracking.mlvt.gov.kh)**



# បន្តពង្រឹង និងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ




កិច្ចប្រជុំគណៈប្រឹក្សាភិបាលលើកទី១ នៃកម្មវិធីមុខរបរ និងការងារសមរម្យ សម្រាប់យុវជននៅកម្ពុជា ដំណាក់កាលទី៣ (DEY III)




កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះទទួលបន្ទុកជំរុញការអនុវត្តផែនទីបង្ហាញផ្លូវរបស់កម្ពុជាសម្រាប់កាតាលីករសកលស្តីពីការងារសមរម្យ និងការគាំពារសង្គមសម្រាប់អន្តរកាលយុត្តិធម៌




ការចុះអនុស្សរណៈជាមួយមូលនិធិការងារអន្តរជាតិជប៉ុន (JILAF) ដើម្បីពង្រឹងការគាំទ្រអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (Informal Economy)

# ១០. ទិសដៅការងារសម្រាប់ឆ្នាំ២០២៦

# ទិសដៅការងារ

១ បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍គន្លឹះទាំង ១០ចំណុចរបស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។

២ បន្តពង្រឹង និងពង្រីកការផ្តល់សេវាការងារ សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ការតម្រង់ទិសមុនចូលទីផ្សារការងារ និងការបន្តរៀបចំព្រឹត្តិការណ៍ការងារ រួមមាន វេទិកាការងារ ពិព័រណ៍ការងារ និងការផ្គូផ្គងនិងសម្ភាសការងារ និងការពង្រឹងប្រសិទ្ធភាពនៃដំណើរការប្រព័ន្ធស្វែងរកការងារ បន្ទាន់តាមទូរសព្ទ ១២៩៧ ដល់សាធារណជន និងជាពិសេសបងប្អូនដែលត្រឡប់មកពីប្រទេសថៃ។

៣ បន្តពង្រីកទីផ្សារការងារនៅក្រៅប្រទេស ដែលមានប្រាក់ឈ្នួលខ្ពស់ លក្ខខណ្ឌការងារល្អ និងមានជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

# ទិសដៅការងារ (បន្ត)

៤

បន្តរៀបចំ ផលិត និងផ្សព្វផ្សាយរបាយការណ៍អង្កេតនិងឯកសារសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងតម្រូវការទីផ្សារការងារ ជាពិសេស ទស្សនវិស័យមុខរបរនិងការងារ ឱ្យបានទៀងទាត់ ដើម្បីផ្តល់ព័ត៌មានទីផ្សារការងារឱ្យបានគ្រប់ជ្រុងជ្រោយ ដល់អ្នកស្វែងរកការងារ កម្មករនិយោជិត និយោជក អ្នកផ្តល់ការបណ្តុះបណ្តាល និងសាធារណជន។

៥

បន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ ការគាំពារជនទេសន្តរប្រវេសន៍ការងារខ្មែរទៅធ្វើការនៅក្រៅប្រទេស និងយន្តការសមាហរណកម្មជនទេសន្តរប្រវេសន៍ការងារខ្មែរប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

# ទិសដៅការងារ (បន្ត)

**៦** បន្តពង្រឹងយន្តការអធិការកិច្ចអន្តរក្រសួង និងប្រព័ន្ធអភិបាលកិច្ចអធិការកិច្ចការងារតាមរយៈការកំណត់គុណវុឌ្ឍិអធិការការងារ និងយុទ្ធសាស្ត្រអធិការកិច្ចការងារផ្អែកលើកម្រិតហានិភ័យរបស់សហគ្រាស ក្រុមហ៊ុន រោងចក្រ សំដៅបង្កើនជំនឿទុកចិត្តរបស់និយោជក កម្មករនិយោជិត និងភាគីពាក់ព័ន្ធលើអធិការការងារ ដោយឈរលើអភិក្រមអនុវត្តចំនួន ៤ ដូចខាងក្រោម៖

**៦.១** គោលដៅចុងក្រោយនៃការធ្វើអធិការកិច្ចការងារ មិនមែនការផាកពិន័យទេ គឺជាការធានានូវអនុលោមភាពនៃច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាប្រតិបត្តិ។

**៦.២** រៀបចំឯកសារទាំងជាអក្សរ ជាសំឡេង ជាវីដេអូ ដើម្បីពន្យល់ បកស្រាយ ដោយលំហូរការងារជាភាសាសាមញ្ញ ងាយយល់ សម្រាប់សាធារណជនទូទៅ។

**៦.៣** អធិការការងារ អធិការពេទ្យការងារ និងមន្ត្រីផ្សះផ្សាត្រូវមានសមត្ថភាពយល់ដឹងនិងបកស្រាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ប្រកបដោយសង្គតិភាព ព្រមទាំងជំរុញការអនុវត្តស្វ័យប្រកាសអធិការកិច្ចការងារ។

**៦.៤** ផ្តល់ការបណ្តុះបណ្តាលដល់មុខសញ្ញាដែលងាយរងហានិភ័យឱ្យយល់ដឹងពីយន្តការជូនដំណឹងដល់ក្រសួង និងមន្ត្រីមានសមត្ថកិច្ច មុនគេ។

# ទិសដៅការងារ (បន្ត)

៧

បន្តលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ នៅកន្លែងការងារ តាមរយៈការពង្រឹងសមត្ថភាពរបស់ "គណៈកម្មការសុវត្ថិភាព និងសុខភាពការងារនៅតាមសហគ្រាស" ដែលមានស្រាប់ និងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងដៃគូសង្គមបំពាក់សម្ភារៈ បរិក្ខារស្វ័យប្រវត្តិ ដោយភ្ជាប់នឹងប្រព័ន្ធតាមដានជាសកល និងដាក់ផ្ទាំងព័ត៌មាន (LED) ពាក់ព័ន្ធនឹងបទដ្ឋានសុវត្ថិភាពនិងសុខភាពការងារ (OSH) នៅក្នុងអគារផលិតកម្មនីមួយៗ ដើម្បីប្រតិភូបុគ្គលិក និងបងប្អូនកម្មករនិយោជិត អ្នកបញ្ជាទិញ និងអធិការពេទ្យការងារអាចតាមដាន និងវាយតម្លៃស្ថានភាពជាក់ស្តែងបានគ្រប់ពេលវេលា ដោយផ្តើមចេញពីវិស័យកាត់ដេរ ហើយនិយោជកនឹងមិនមានបន្ទុកចំណាយលើការដាក់ឱ្យដំណើរការប្រព័ន្ធនេះឡើយ។ បន្តសហការជាមួយដៃគូ និងភាគីពាក់ព័ន្ធបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ (OSH)។

៨

បង្កើនកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការលុបបំបាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារជាពិសេសក្នុងវិស័យដែលមានហានិភ័យខ្ពស់។

# ទិសដៅការងារ (បន្ត)

៩

បន្តអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ប្រតិភូបុគ្គលិក បុគ្គលទទួលបន្ទុកផ្នែករដ្ឋបាលនិងធនធានមនុស្ស និយោជក និងកម្មករនិយោជិត ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ។

១០

បន្តពង្រឹងប្រសិទ្ធភាព យន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ តាមរយៈការដាក់ចេញនូវយន្តការបង្ការ និងដោះស្រាយវិវាទការងារនៅកម្រិតសហគ្រាស និងការអភិវឌ្ឍសមត្ថភាពអ្នកផ្សះផ្សាវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល។

១១

បន្តពង្រីកវិសាលភាពគ្របដណ្តប់របបសន្តិសុខសង្គម ឱ្យបានជាអតិបរមា តាមរយៈការសិក្សាសមិទ្ធិលទ្ធភាពនៃការពង្រីកនិងរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ចុះបញ្ជីក្រុមគោលដៅ ដែលមិនទាន់គ្របដណ្តប់តាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ជាពិសេសអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

# ទិសដៅការងារ (បន្ត)

១២

បន្តលើកកម្ពស់អនុលោមភាពនៃការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូទាំងអស់ និងរៀបចំវេទិកាជាមួយតំណាងភាគីពាក់ព័ន្ធ (មូលដ្ឋានសុខាភិបាល ធនាគារដៃគូ ភាគីនិយោជក និងតំណាងសមាជិក ប.ស.ស.) ជារៀងរាល់ត្រីមាស ដើម្បីពិភាក្សាដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា សំដៅលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពនៃការផ្តល់សេវារបស់ ប.ស.ស. ឱ្យកាន់តែប្រសើរឡើង។

១៣

បន្តជំរុញការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសជូនដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួន ១,៥លាននាក់ ឱ្យស្របទៅតាមតម្រូវការឧស្សាហកម្ម និងជំរុញការអនុវត្តការទទួលស្គាល់ជំនាញពីមុន របស់បងប្អូនអតីតពលករខ្មែរមកពីប្រទេសថៃ ក្នុងវិស័យអាទិភាព ដែលចាប់ផ្តើមពីវិស័យសំណង់ លើ ៨មុខជំនាញ នៅក្នុងខែមេសា ឆ្នាំ២០២៦ ខាងមុខនេះ ដោយរាជរដ្ឋាភិបាល ជាអ្នកបង់ថ្លៃធ្វើតេស្តជំនួស។

# ទិសដៅការងារ (បន្ត)

១៤ បន្តជំរុញនិងផលិតផ្ទាក់បណ្តុះបណ្តាលចល័តឱ្យកាន់តែច្រើន និងទំនើបដើម្បីបង្កិតការបណ្តុះបណ្តាលឱ្យកាន់តែជិតអ្នកដែលមានតម្រូវការក្នុងការបណ្តុះបណ្តាល។ ពង្រីកការកែច្នៃម៉ូតូកង់បី ដើម្បីបង្កើនចំណូលដល់អ្នកមានមុខរបរបើកបរត្រីចក្រយានយន្ត ឬលក់ដូរចល័ត។

១៥ ចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តឱ្យបានជោគជ័យកម្មវិធីគន្លងអប់រំថ្មី ដែលនឹងចាប់ផ្តើមអនុវត្តសាកល្បងចាប់ពីឆ្នាំសិក្សា២០២៦-២០២៧ តទៅ សំដៅផ្តល់ជម្រើសបន្ថែមដល់សិស្សវិទ្យាល័យ ដែលស្ថិតនៅក្បែរតំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្ម ហើយមានបំណងចូលទៅកាន់ទីផ្សារការងារលឿន អាចជ្រើសរើសយកគន្លងវិជ្ជាជីវៈ នៅវិទ្យាល័យរបស់ខ្លួន។

១៦ បញ្ចប់ការរៀបចំគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ។

# ទិសដៅការងារ (បន្ត)

១៧

បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាព ប្រសិទ្ធភាព និងគុណភាពនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

១៨

បន្តពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចនិងរដ្ឋបាលការងាររបស់ក្រសួង តាមរយៈការធ្វើឌីជីថលនីយកម្មបន្ថែមទៀតនូវរាល់សកម្មភាពអធិការកិច្ចការងារ សេវាសាធារណៈ និងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យវិស័យការងារ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការបណ្តុះបណ្តាលជំនាញ ប្រព័ន្ធគ្រប់គ្រងទិន្នន័យសន្និធិជំនាញ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការធ្វើតេស្តសមត្ថភាពជំនាញពីមុន ប្រព័ន្ធគ្រប់គ្រងទិន្នន័យបេឡាជាតិសន្តិសុខសង្គម និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារនៅកន្លែងធ្វើការ ព្រមទាំងបំពាក់បន្ថែមនូវសម្ភារៈនិងឧបករណ៍វៃឆ្លាតដើម្បីជាជំនួយដល់ក្រុមអធិការកិច្ចការងារ និងអង្គភាពក្រោមឱវាទក្រសួង។

# ទិសដៅការងារ (ចប់)

១៩

រៀបចំសេចក្ដីណែនាំជាឯកសារ ជាសំឡេង និងជាឃ្លីបវីដេអូ ដោយប្រើភាសាសាមញ្ញ និងលំហូរការងារកាន់តែសាមញ្ញថែមទៀតសំដៅឱ្យតួអង្គពាក់ព័ន្ធគ្រប់ស្រទាប់វណ្ណៈ អាចយល់ និងចូលរួមអនុវត្តកាន់តែច្រើន និងល្អស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឧត្តមានុវត្តន៍ជាសកល ដែលពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

*សូមអរគុណ!*